ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

លេខ....០៥៣.....បទ..........................

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥

# សារលិខិតសំដែងមរណទុក្ខ

**សូមគោរពជូន**
**ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ថ្នាក់នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានសេចក្តីតក់ស្លុតរន្ធត់ចិត្តឥតឧបមា ដោយទទួលបានដំណឹងដ៏សែនក្រៀមក្រំបំផុត ដោយ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា** នៃព្រះរាជាណាចក្រកម្ពុជា បានទទួលមរណភាពកាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ វេលាម៉ោង ១៥:៤៥ នាទី ក្នុងជន្មាយុ ៨៣ឆ្នាំ ដោយរោគាពាធ។

ក្នុងឱកាសដ៏មហាសែនក្រៀមក្រំនេះ ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ថ្នាក់នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវសមានចិត្តដ៏សែនក្តុកក្តួលយ៉ាងក្រៃលែងជាមួយនឹងការសោកស្តាយក្រៀមក្រំ និងអាឡោះអាល័យបំផុត និងសូមចូលរួមរំលែកទុក្ខជាមួយឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ ព្រមទាំងបុត្រា បុត្រីនៃសព និងសូមបួងសួងឲ្យវិញ្ញាណក្ខន្ធសព **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** បានយោនយកកំណើតក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

**រដ្ឋមន្ត្រី**

ប្រាក់_សុខុន